# មាតិកា

## I. សេចក្តីណែនាំ

1. ការចូលទៅកាន់គេហទំព័រមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាលសំរាប់ការស្នើសុំត្រួតពិនិត្យគុណភាព ឱសថ និង ផលិតផលសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា

2. ការបង្កើតគណនីយរបស់អ្នកប្រើប្រាស់នៅក្នុងប្រព័ន្ធ

3. ការចូលទៅកាន់ការប្រើប្រាស់ប្រព័ន្ធ

4. ការចូលទៅបង្កើតផលិតផលសំណាក និង ការដាក់ស្នើរផលិតផលសំណាក

5. ណែនាំពីការបង្កើតសមាជិកអ្នកប្រើប្រាស់ផ្សេងទៀតជាកូនក្រុមរបស់ខ្លួនដើម្បីអោយអ្នកប្រើប្រាស់ក្នុងក្រុមខ្លួនអាចបង្កើតបានដូចខ្លួនដែរ

6. ណែនាំអំពីការចង់ចាំគណនីសំរាប់ចូលទៅកាន់ប្រព័ន្ធ

7. ណែនាំអំពីការភ្លេចគណនីសំរាប់ចូលទៅកាន់ប្រព័ន្ធ

# ការពិពណ៌នា

## 1. ការចូលទៅកាន់គេហទំព័រមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាលសំរាប់ការស្នើសុំត្រួតពិនិត្យ គុណភាព ឱសថ និង ផលិតផលសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា




ដើម្បីចូលទៅកាន់គេហទំព័រដូចរូបខាងលើសូមចុចដំណភ្ជាប់ខាងក្រោម

hqconlineregistration.nhqc.org.kh

ក្រោយពីចុចដំណភ្ជាប់នេះហើយអ្នកនិងឃើញដូចរូចខាងលើដោយយោងតាមរូបខាងលើខ្ញុំសូមធ្វើការបង្ហាញទាក់ទងនិងមុខងារមួយចំនួននៅលើគេហទំព័រមួយនេះដូចខាងក្រោមជាដំណាក់ៗ

## 2. ការបង្កើតគណនីយរបស់អ្នកប្រើប្រាស់នៅក្នុងប្រព័ន្ធ

- **យោងតាមរូបចំណុចលេខ1ដាក់ថាពុំមានគណនី?ចុចទីនេះដើម្បីបង្កើតគណនី** សំរាប់ចូលទៅកាន់គេហទំព័រថ្មីមួយទៀតដើម្បីបង្កើតគណនីដើម្បីចូលទៅប្រើប្រាស់ប្រព័ន្ធស្នើសុំត្រួតពិនិត្យគុណភាព ឱសថ និង ផលិតផលសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។សូមចុចលើពាក្យ**ចុចទីនេះដើម្បីបង្កើតគណនី**




តាមរូបខាងលើសូមបញ្ចូលឈ្មោះ អ៊ីម៉ែល និង ពាក្យសំងាត់បន្ទាប់ពីបញ្ចូលសព្វគ្រប់ហើយសូមចុចលើប៊ូតុងចុះឈ្មោះថ្មីឃើញដូចរូបខាងក្រោម




រូបភាពនេះបញ្ជាក់ថាអ្នកបានបង្កើតគណនីបានដោយជោគជ័យបន្ទាប់មកសូមចូលទៅកាន់អ៊ីម៉ែលរបស់អ្នកដែលបានយកមកបង្កើតគណនីដើម្បីទទួលយកគណនីដែលអ្នកបានបង្កើត។ពេលចូលទៅអ៊ីម៉ែលរបស់អ្នកនិងឃើញសាររបស់ LIMS រួចចុចលើសារនេះអ្នកនិងឃើញដូចរូបខាងក្រោម




សូមចុចលើពាក្យ Activate Now ដើម្បីទទួលយកគណនីរបស់អ្នក។បន្ទាប់ពីចុច

Activate Now ហើយអ្នកនិងឃើញដូចរូបខាងក្រោម




សូមចុចលើពាក្យ សូមចុចទីនេះដើម្បីចូលទៅកាន់គេហទំព័របង្កើតផលិតផលសំណាក ឬ អាចវាយបញ្ចូល អ៊ីម៉ែល និង ពាក្យសំងាត់រួចចុចលើប៊ូតុងចូលប្រើប្រាស់ប្រព័ន្ធ។ ក្រោយមកអ្នកនិងឃើញគេហទំព័រដូចខាងក្រោម




## 3. ការចូលទៅកាន់ការប្រើប្រាស់ប្រព័ន្ធ

ពេលអ្នកបានបង្កើតគណនីយរួចហើយអ្នកអាចចូលប្រើប្រាស់ប្រព័ន្ធបានរាល់ពេលអ្នក login ។

ដោយគ្រាន់តែវាយបញ្ចូលអ៊ីម៉ែល និង ពាក្យសំងាត់របស់អ្នក។




## 4. ការចូលទៅបង្កើតផលិតផលសំណាក និង ការដាក់ស្នើផលិតផលសំណាក

ពេលអ្នកចូលមកដល់ខាងក្នុងប្រព័ន្ធសូមចុចលើមីនុយដែលដាក់ថាការគ្រប់គ្រងផលិតផលពេលនោះ អ្នកនិងឃើញដូចរូបខាងក្រោម




ដើម្បីបង្កើតផលិតផលសូមចុចលើប៊ូតុងបន្ថែមថ្មីបន្ទាប់មកអ្នកនិងឃើញរូបខាងក្រោម



តាមរូបខាងលើនេះជាទំរង់បញ្ចូលផលិតផលសំណាកសូមបញ្ចូលទិន្នន័យរួចចុចរក្សាទុក។ពេលអ្នករក្សាទុករួចហើយវានិងនាំអ្នកទៅកាន់ផ្នែកទីពីរដូចខាងក្រោម


ទំព័រដើម
ការគ្រប់គ្រងផលិតផល
ការគ្រប់គ្រងអ្នកប្រើប្រាស់
ភាសាខ្មែរ
ទ្រី ស្រីទូច
1
ព័ត៌មានសំណាក
2
បែបបទស្នើសុំមន្ទីរពិសោធន៍ធ្វើតេស្ត
3
ទម្រង់វាយតម្លៃ
4
បង់ប្រាក់
បែបបទស្នើសុំមន្ទីរពិសោធន៍ធ្វើតេស្ត
រក្សាទុក
ត្រលប់ក្រោយ
អ្នកវាយតម្លៃ *
Please Re.Evaluator
ព័ត៌មានបេក្ខជន
ឈ្មោះក្រុមហ៊ុន / ទីភ្នាក់ងារ *
ឈ្មោះក្រុមហ៊ុន / ទីភ្នាក់ងារ
នាយក / ឈ្មោះតំណាង*
នាយក / ឈ្មោះតំណាង
ឱសថការី / ឈ្មោះតំណាង *
ឱសថការី / ឈ្មោះតំណាង
ទូរស័ព្ទ*
ទូរស័ព្ទ
អ៊ីម៉ែល *
trysreytouch34@gmail.com
គេហទំព័រ
គេហទំព័រ
បណ្ដាញសង្គម
បណ្ដាញសង្គម
អាសយដ្ឋានក្រុមហ៊ុន
អាសយដ្ឋានក្រុមហ៊ុន
Documents Requirement:
Analysis Requested for Registration
Analysis Requested for Non-Registration
CoPP (Scan Document)
MoH Brand Name Approval Copied (Scan Document)
Unit & Batch Formula / Composition (Upload / Scan Document)*
Specification & Analytical Procedure of API with CoA (Upload / Scan Document)*
Specification & Analytical Procedure of Finish Products with CoA (Upload / Scan Document)*
Stability Study Protocol & Report Data (Real time and Accelerated time) (Upload/Scan Document)*
Outer Labels*
Inner Labels
Blisters/Strips
Request Testing Parameters:
Full Test Parameters or Select Parameters (For Non-Registration Only) :
Full Parameter
Select Parameters (For Non-Registration Only)
1. ឱសថគ្រាប់ដូចជា Coated, Uncoated, Chewable, Tablets, Capsules, Pills, Granules :
2. ឱសថ Suppositories, Pessaries :
3. ឱសថម្សៅប្រើតាមមាត់ដូចជា Oral liquid, Powder for Oral Suspension / Solution :
4. ឱសថម្សៅ ឬ Solution សម្រាប់ចាក់តាមសាច់ដុំ, សរសៃ ឬតាមសរីរាង្គខាងក្នុងដូចជា Powder for Injection, Solution for Injection / Infusion :
5. ទឹកលាយឱសថ (Solvent) :
6. វិភាគវត្ថុធាតុដើម Raw Material / Active Ingredient Substance :
7. ផលិតផលផ្សេងៗទៀតដែលត្រូវវិភាគបាក់តេរីសាស្ត្រ (Sterile and Non Sterile Products) :
រក្សាទុក
ត្រលប់ក្រោយ

នេះជាទំរង់បញ្ចូលបែបបទស្នើសុំមន្ទីរពិសោធន៍ធ្វើតេស្ត។សូមធ្វើការបញ្ចូលទិន្នន័យរួចចុចរក្សាទុក។ ក្រោយពេលរក្សាទុកហើយវានិងចេញប៊ូតុងចំនួនពីរទៀតគឺប៊ូតុង ដាក់ស្នើ និង បោះពុម្ព ដូចរូបខាងក្រោម



អ្នកអាចធ្វើការកែប្រែបានដោយចុចលើប៊ូតុងកែប្រែ។

ដើម្បីដាក់ស្នើផលិតផលសំណាករបស់អ្នកសូមចុចលើប៊ូតុងដាក់ស្នើ។បន្ទាប់ពីអ្នកដាក់ស្នើរួចវានិងលោតសារបញ្ជាក់ថាអ្នកពិតជាចង់ដាក់ស្នើមែនទេ?ដូចរូបខាងក្រោម




បើអ្នកប្រាកដចង់ដាក់ស្នើសូមចុចយល់ព្រមពេលនោះវានិងនាំអ្នកមកកាន់បញ្ជីឈ្មោះផលិតផលដែលអ្នកបានបង្កើតដូចរូបខាងក្រោម




បន្ទាប់ពីអ្នកដាក់ស្នើនូវផលិតផលសំណាករបស់អ្នកគឺអ្នកត្រូវរងចាំរហូតដល់អ្នកត្រួតពិនិត្យគាត់ទទួលយកការដាក់ស្នើរបស់អ្នក។អ្នកអាចដឹងថាផលិតផលដែលអ្នកដាក់ស្នើនោះត្រូវបានគេត្រួតពិនិត្យឬនៅដោយអ្នកអាចមើលនៅត្រង់តារាងដោយទាញទៅកាន់ផ្នែកខាងចុងបន្តិចដែលដាក់ថាស្ថានភាពពេលនោះអាចឃើញពាក្យដូចជា

- **កំពុងរង់ចាំ** ៖ ចេញពាក្យនេះពេលដែលបង្កើតផលិតផលហើយមិនទាន់ដាក់ស្នើ
- **បានដាក់ស្នើសុំ** ៖ ចេញពាក្យនេះពេលដែលផលិតផលត្រូវបានដាក់ស្នើសុំ
- **ពិនិត្យឡើងវិញ** ៖ ចេញពាក្យនេះពេលដែលអ្នកត្រួតពិនិត្យទទួលយកនិងធ្វើការត្រួតពិនិត្យលើការដាក់ស្នើ
- **បង់ប្រាក់** ៖ ចេញពាក្យនេះពេលដែលគេធ្វើទម្រង់វាយតម្លៃ រួចនិងការបង់ប្រាក់សំរាប់ផលិតផលដែលបានដាក់ស្នើសុំ
- **បដិសេធ** ៖ ចេញពាក្យនេះពេលដែលអ្នកវាយតម្លៃគាត់បដិសេធនូវការដាក់ស្នើផលិតផលរបស់អ្នក

- **កំពុងដំណើរការ** ៖ចេញពាក្យនេះនៅពេលដែលអ្នកបានបំពេញនូវការបង់ប្រាក់រួចដាក់ស្នើ បន្ទាប់មកខាងអ្នកទទួលប្រាក់គាត់ទទួលយកនៅការបង់ប្រាក់របស់អ្នក
- **បញ្ចេញលទ្ធផល** ៖មានន័យថាផលិតផលរបស់អ្នកបានដាក់ស្នើដោយជ័យ

ខាងក្រោមនេះជារូបដែលបង្ហាញផលិតផលដែលបានដាក់ស្នើសុំ




**ពេលដែលអ្នកឃើញត្រង់ក្រឡោនស្ថានភាពប្តូរទៅជាពាក្យថាបដិសេធអ្នកចូលទៅមើលការវាយតម្លៃរបស់អ្នកត្រួតពិនិតបានដោយចុចប៊ូតុងពណ៌ទឹកប៊ិចនៅក្នុងក្រឡោនសកម្មភាពរូបខាងលើរួចមើលនៅលើផ្នែកទីពាទម្រង់វាយតម្លៃត្រង់ Missing Points Note អ្នកនិងឃើញពីមូលហេតុដែលគេបដិសេធការដាក់ស្នើរបស់អ្នក។ពេលនោះអ្នកអាចធ្វើការកែប្រែរាល់ Missing Points Note ដែលអ្នកវាយតម្លៃបានប្រាប់អ្នករួចអ្នកអាចធ្វើការដាក់ស្នើម្តងទៀតបាន

**ពេលដែលអ្នកឃើញត្រង់ក្រឡោនស្ថានភាពប្តូរទៅជាពាក្យថាបង់ប្រាក់មានន័យថាផលិតផលរបស់អ្នកត្រូវបានគេវាយតម្លៃរួចហើយរងចាំការបង់ប្រាក់របស់អ្នក។អ្នកអាចចូលទៅបង់ប្រាក់នៅផ្នែកទី៤នៃទំរង់បញ្ចូលផលិតផលសំណាក។របៀបចូលសូមចុចលើប៊ូតុងពណ៌ទឹកប៊ិចដូចរូបខាងក្រោម




ពេលចុចលើប៊ូតុងនេះរួចអ្នកត្រូវចុចលើលេខ៤ដាក់ថាបង់ប្រាក់ ដូចរូបខាងក្រោម



តាមរូបខាងលើនេះយើងបែងចែកការបង់ប្រាក់ជាពីផ្នែកគឺ

- 1 វិធីសាស្រ្តទូទាត់ ជាវិធីសាស្រ្តមួយដែលអ្នកអាចបង់លុយបានតាមរយៈ
  - អេស៊ីលីដា (ACLEDA)
  - វីង (WING)
  - អេប៊ីអេ (ABA)
- 2 ឬភ្នាក់ងារផ្ទេរប្រាក់ ជាវិធីសាស្រ្តមួយដែលអ្នកអាចបង់តាមភ្នាក់ងារផ្ទេរប្រាក់ផ្សេងៗទៀត

❖ របៀបបញ្ចូលការបង់ប្រាក់

- វិធីសាស្រ្តទូទាត់
  - បើអ្នកជ្រើសរើសវិធីសាស្រ្តទី១សូមចុចយកវិធីសាស្រ្តទូទាត់ មើលរូបខាងលើរួចអ្នកអាចផ្ញើរប្រាក់តាម អេស៊ីលីដា (ACLEDA) ឬ វីង(WING) ឬ អេប៊ីអេ (ABA)តាមលេខគណនីនីមួយៗដូចរូបខាងលើ។បន្ទាប់ពីអ្នកផ្ញើប្រាក់រួចហើយសូមថតវិក័យបត្រទុកសំរាប់បង្កើតការបង់ប្រាក់
  - សូមបញ្ចូលកាលបរិច្ឆេទ និង វិក័យបត្រដែលអ្នកបានថតនោះដោយចុចត្រង់ពាក្យថាសូមភ្ជាប់ច្បាប់ចម្លងនៃបង្កាន់ដៃបង់ប្រាក់របស់អ្នក
  - សូមចុចរក្សាទុកពេលរក្សាទុករួចរាល់អ្នកនិងឃើញមានលេចចេញនៅប៊ូតុងមួយទៀតដាក់ថា ដាក់ស្នើបើសិនជាអ្នកមិនទាន់ដាក់ស្នើនោះអ្នកអាចធ្វើការកែប្រែការ

បង់ប្រាក់របស់អ្នកបានតែបើអ្នកដាក់ចុចដាក់ស្នើនោះអ្នកមិនអាចធ្វើការកែប្រែបានទេ។ដូចនេះការបង់ប្រាក់របស់អ្នកជោគជ័យនៅពេលអ្នកចុចប៊ូតុងដាក់ស្នើ។



- ភ្នាក់ងារផ្ទេរប្រាក់

- សូមចុចលើឬភ្នាក់ងារផ្ទេរប្រាក់ រួចសូមបញ្ចូលឈ្មោះភ្នាក់ងារផ្ទេរប្រាក់ លេខកូដភ្នាក់ងារផ្ទេរប្រាក់ ទូរស័ព្ទរបស់អ្នកផ្ញើ ទូរស័ព្ទរបស់អ្នកទទួល កាលបរិច្ឆេទ សូមភ្ជាប់ច្បាប់ចម្លងនៃបង្កាន់ដៃបង់ប្រាក់របស់អ្នក
- សូមចុចរក្សាទុកពេលរក្សាទុករួចរាល់អ្នកនិងឃើញមានលេចចេញនៅប៊ូតុងមួយទៀតដាក់ថា ដាក់ស្នើបើសិនជាអ្នកមិនទាន់ដាក់ស្នើនោះអ្នកអាចធ្វើការកែប្រែការបង់ប្រាក់របស់អ្នកបានតែបើអ្នកដាក់ចុចដាក់ស្នើនោះអ្នកមិនអាចធ្វើការកែប្រែបានទេ។ដូចនេះការបង់ប្រាក់របស់អ្នកជោគជ័យនៅពេលអ្នកចុចប៊ូតុងដាក់ស្នើ។

បន្ទាប់ពីអ្នកធ្វើការដាក់ស្នើការបង់ប្រាក់រួចហើយខាងអ្នកទទួលលុយគេនិងចុចទទួលយកការបង់ប្រាក់របស់អ្នកពេលនោះអ្នកនិងឃើញពាក្យ**កំពុងដំណើរការ**ដូចបង្ហាញរៀបរាប់ពីការចេញនៅក្នុងក្រឡោនស្ថានភាពខាងលើ។បន្ទាប់មកប្តូរទៅជាពាក្យ**បញ្ចេញលទ្ធផល**មានន័យថាផលិតផលដែលអ្នកដាក់ស្នើត្រូវបានដាក់ស្នើដោយជោគជ័យ។

## 5. ណែនាំពីការបង្កើតសមាជិកអ្នកប្រើប្រាស់ផ្សេងទៀតជាកូនក្រុមរបស់ខ្លួនដើម្បីអោយអ្នកប្រើប្រាស់ក្នុងក្រុមខ្លួនអាចបង្កើតបានដូចខ្លួនដែរ

ដើម្បីបង្កើតអ្នកប្រើប្រាស់ផ្សេងទៀតសូមអ្នកចុចនៅលើពាក្យការ**គ្រប់គ្រងអ្នកប្រើប្រាស់**សូមមើលរូបខាងក្រោម




តាមរូបក្រោយពីអ្នកចុចការគ្រប់គ្រងអ្នកប្រើប្រាស់រួចនិងចេញតារាងពត៌មានអ្នកប្រាស់ដែលអ្នកបានបង្កើត។ដើម្បីបង្កើតសូមចុចលើពាក្យបន្ថែមថ្មីមើលរូបគឺត្រង់លេខ3ពេលនោះនិងលោតផ្ទាំងមួយមកដាក់ថាបង្កើត។សូមបញ្ចូលព័ត៌មានរួចចុចត្រង់លេខ4ដែលដាក់ថារក្សាទុកបើអ្នកមិនចង់រក្សាទុកសូមចុចលើលេខ5ដាក់ថាបោះបង់។បើអ្នកចុចរក្សាទុករួចអ្នកនិងបានព័ត៌មានអ្នកប្រើប្រាស់ដែលអ្នកបានបង្កើតសូមមើលរូបខាងក្រោម




ក្រោយពីអ្នកបង្កើតគណនីមួយសំរាប់អ្នកប្រើប្រាស់ម្នាក់ឈ្មោះថា sovanara ដែលមានអ៊ីមែល sovanara@gmial.com ។ដូចនេះ sovanara គាត់អាចបង្កើតផលិតផលសំរាប់ដាកស្នើដូចអ្នកដែរដោយបង្កើតផលិតផលដោយប្រើឈ្មោះក្រុមហ៊ុនមួយរួមជាមួយនិងអ្នកដែរ។

## 6. ណែនាំអំពីការចង់ចាំគណនីសំរាប់ចូលទៅកាន់ប្រព័ន្ធ

ដើម្បីចងចាំគណនីចូលទៅកានប្រព័ន្ធសូមចុចលើពីថា**ចងចាំពាក្យសម្ងាត់របស់អ្នក**មុនពេលចុចចូលប្រើប្រាស់ប្រព័ន្ធសូមមើលរូប




ក្រោយពីចុច**ចងចាំពាក្យសម្ងាត់របស់អ្នក**ហើយលោកក្រោយអ្នកមិនបាច់វាយអ៊ីមែលនិងពាក្យសំងាត់ទេវាមានស្រាប់ចុចចុចចូលប្រើប្រព័ន្ធតែម្តង។

## 7. ណែនាំអំពីការភ្លេចគណនីសំរាប់ចូលទៅកាន់ប្រព័ន្ធ

នៅពេលអ្នកភ្លេចនូវពាក្យសំងាត់របស់អ្នកនោះអ្នកអាចធ្វើការផ្លាស់ប្តូរបានដោយចុចលើពាក្យថា **ភ្លេចពាក្យសំងាត់?**